ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
[illegible]
លេខ: 7

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបំពេញកាតព្វកិច្ចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

បន្ទាប់ពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ក្រសួងមហាផ្ទៃកត់សម្គាល់ឃើញមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនដែលបានចុះបញ្ជី និងតម្កល់សំណុំឯកសារនៅក្រសួងមហាផ្ទៃ បានយកចិត្តទុកដាក់អនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយ **មាត្រា ១០** និង **មាត្រា ២៥** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទន្ទឹមនេះ ក៏មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន មិនបានយកចិត្តទុកដាក់អនុវត្តតាមបទប្បញ្ញត្តិនៃមាត្រាខាងលើ និងបានអនុវត្តផ្ទុយនឹងលក្ខន្តិកៈរបស់ខ្លួនថែមទៀត។

ដើម្បីជានាឲ្យការចូលរួមអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងលើកកម្ពស់នីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ មានកិត្តិយសសូមជម្រាបជូនដល់គ្រប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដូចតទៅ៖

១. សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជី និងតម្កល់សំណុំឯកសារនៅក្រសួងមហាផ្ទៃ ត្រូវបំពេញនូវកាតព្វកិច្ចដូចខាងក្រោម៖

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជា មកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាម **មាត្រា ១០** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល **ឲ្យបានមុនដំណាច់ខែកញ្ញា ឆ្នាំ២០១៧ ជាកំណត់**។
- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួលដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ។

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ស្របតាម **មាត្រា ២៥** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនឲ្យហួសពី**ដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់**។ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥(ប្រាំ)ឆ្នាំ។ ចំពោះរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០១៦ ត្រូវផ្ញើមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានមុនដំណាច់**ខែកញ្ញា ឆ្នាំ២០១៧** ជាកំណត់។

២. ករណីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាមួយ ខកខានមិនបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច១ ខាងលើ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវទទួលវិធានការតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៧

**ក្រសួងមហាផ្ទៃ**